



## អត្ថប្រយោជន៍ធានារ៉ាប់រង៖

**1 ទឹកប្រាក់ត្រលប់តាមកាលកំណត់៖** ផ្តល់ជូនទឹកប្រាក់ត្រលប់តាមកាលកំណត់5% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងនៅចុងឆ្នាំទី3 នៃផលិតផលនេះ ប្រសិនបើមិនមានការទាមទារសំណងលើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។

**2 អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីមូលហេតុទូទៅ៖**

- ផ្តល់ជូនទឹកប្រាក់សំណង 100% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។
- ក្នុងករណីដែលអត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីមូលហេតុទូទៅត្រូវបានទូទាត់រួច ក្រុមហ៊ុនមិនតម្រូវឱ្យលោកអ្នកបង់បុព្វលាភធានារ៉ាប់រងបន្តទៀតឡើយ ប៉ុន្តែក្រុមហ៊ុននៅតែធានាទូទាត់ជូនអត្ថប្រយោជន៍ដល់កាលកំណត់។

**3 អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ បណ្តាលមកពីគ្រោះថ្នាក់៖**

- ផ្តល់ជូនទឹកប្រាក់សំណងបន្ថែម 200% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីគ្រោះថ្នាក់។
- ក្នុងករណីដែលអត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីគ្រោះថ្នាក់ត្រូវបានទូទាត់រួច ក្រុមហ៊ុនមិនតម្រូវឱ្យលោកអ្នកបង់បុព្វលាភធានារ៉ាប់រងបន្តទៀតឡើយ ប៉ុន្តែក្រុមហ៊ុននៅតែធានាទូទាត់ជូនអត្ថប្រយោជន៍ដល់កាលកំណត់។

**4 អត្ថប្រយោជន៍ដល់កាលកំណត់៖**

ផ្តល់ជូនអត្ថប្រយោជន៍ដល់កាលកំណត់ 105% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងដែលនឹងត្រូវទូទាត់ជូននៅកាលបរិច្ឆេទដល់កាលកំណត់នៃផលិតផលនេះ ដោយមិនអាស្រ័យ ថាអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍នោះឡើយ។

## ដំណើរការរបស់ផលិតផល៖

លោកសម្បត្តិ អាយុ 35ឆ្នាំ ទិញ ផលិតផលិតផល ForLife ចម្រើនទ្រព្យ ដើម្បីការពារខ្លួនគាត់ និងក្តីស្រមៃរបស់គ្រួសារគាត់ ដែលមានរយៈពេល 15ឆ្នាំ ជាមួយនឹងចំនួនទឹកប្រាក់ធានារ៉ាប់រង 10,000 ដុល្លារ។ លោកសម្បត្តិត្រូវទូទាត់បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំចំនួន 709 ដុល្លារ ។

- រហូតដល់ចុងឆ្នាំទី3នៃផលិតផលនេះ ប្រសិនបើលោកសម្បត្តិ មិនមានជួបប្រទះនូវហេតុការណ៍អកុសលដែលត្រូវបានការពារក្រោមផលិតផលនេះ ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ នឹងទូទាត់ទឹកប្រាក់ចំនួន 500 ដុល្លារជាទឹកប្រាក់ត្រលប់តាមកាលកំណត់ជូនដល់គាត់។
- ប្រសិនបើ លោកសម្បត្តិ ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារជំងឺ ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ នឹងទូទាត់ទឹកប្រាក់ចំនួន 10,000 ដុល្លារ ជូនដល់គាត់ ឬក្រុមគ្រួសាររបស់គាត់ ហើយរាល់ចំនួនបុព្វលាភធានារ៉ាប់រងដែលនៅសល់ នឹងមិនតម្រូវឱ្យ លោក សម្បត្តិ បង់បុព្វលាភធានារ៉ាប់រងបន្តទៀតឡើយ តែក្រុមហ៊ុននៅតែធានាផ្តល់ជូនអត្ថប្រយោជន៍ដល់កាលកំណត់។
- ប្រសិនបើ លោកសម្បត្តិ ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ បណ្តាលមកពីគ្រោះថ្នាក់ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ នឹងទូទាត់ទឹកប្រាក់សរុបចំនួន 30,000 ដុល្លារ ជូនដល់គាត់ ឬក្រុមគ្រួសាររបស់គាត់ ហើយរាល់ចំនួនបុព្វលាភធានារ៉ាប់រងដែលនៅសល់នឹងមិនតម្រូវឱ្យលោក សម្បត្តិ បង់បុព្វលាភធានារ៉ាប់រងបន្តទៀតឡើយ តែក្រុមហ៊ុននៅតែធានាផ្តល់ជូនអត្ថប្រយោជន៍ដល់កាលកំណត់។
- មិនថា លោកសម្បត្តិ ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ក្រុមហ៊ុន ហ្វ័រឈូន ឡាយហ្វ៍ នឹងនៅតែទូទាត់ទឹកប្រាក់ចំនួន 10,500 ដុល្លារ ជូនដល់គាត់ ឬក្រុមគ្រួសាររបស់គាត់នៅកាលបរិច្ឆេទដល់កាលកំណត់នៃផលិតផលនេះ។

## ករណីមិនធានា៖

### 1. អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាលមកពីមូលហេតុទូទៅ)៖

ក្រុមហ៊ុននឹងមិនធ្វើការទូទាត់អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាលមកពីមូលហេតុទូទៅ) ប្រសិនបើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ទាំងឡាយណាដែលកើតឡើងដោយផ្ទាល់ ឬប្រយោលបណ្តាលមកពីមូលហេតុណាមួយដូចខាងក្រោម៖

ក. ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ក្នុងរយៈពេលពីរឆ្នាំគិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទបន្តកិច្ចសន្យាធានារ៉ាប់រង (ដោយយកកាលបរិច្ឆេទ ណាមួយចុងក្រោយគេបំផុត) ទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមានវិបល្លាសក៏ដោយ ឬ

ខ. ឆ្លងមេរោគហ៊ីវ (HIV) ឬជំងឺអេដស៍ (AIDS) ឬជំងឺផ្សេងៗទៀតដែលពាក់ព័ន្ធនឹងមេរោគហ៊ីវ (HIV) ឬជំងឺអេដស៍ (AIDS) ឬ

គ. ការប្រើប្រាស់ខុសច្បាប់នូវថ្នាំណាកូទីគ (narcotics) ថ្នាំរំញោច (stimulants) ឬសារធាតុញៀនដទៃទៀត ឬ

ឃ. ទទួលទោសប្រហារជីវិត ឬចូលរួមក្នុងសកម្មភាពខុសច្បាប់ ឬប្រឆាំងនឹងការចាប់ខ្លួនរបស់អាជ្ញាធរ ឬសកម្មភាពលួចចេញពីពន្ធនាគារ ឬ

ង. សកម្មភាពខុសច្បាប់របស់ ម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលដែលរំលោភទៅនឹងបទបញ្ញត្តិនានាដូចដែលបានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ឬ

ច. ពិការភាព កើតឡើងមុនពេលកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទបន្តកិច្ចសន្យាធានារ៉ាប់រង ឬ

ឆ. សង្គ្រាម (ទោះមាន ឬមិនមានការប្រកាសជាមុន) សង្គ្រាមស៊ីវិល ឬជម្លោះប្រដាប់អាវុធផ្សេងៗ ឬ

ជ. ការបង្កគ្រោះថ្នាក់ដោយខ្លួនឯងរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ដែលស្ថិតក្រោមការការពារនៃផលិតផលនេះ ទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមានវិបល្លាសក៏ដោយ ឬ

ឈ. ចូលរួមនៅក្នុងសកម្មភាពហោះហើរលើកលែងតែជាអ្នកដំណើរនៃអាកាសចរណ៍ស៊ីវិលដែលមានកាលវិភាគហោះហើរ ឬ

ញ. បម្រើការងារក្នុងជួរយោធា ឬកងទ័ពជើងទឹកនៅក្នុងអំឡុងពេលដែលមានសង្គ្រាម (ទោះមាន ឬមិនមានការប្រកាសជាមុន) ឬនៅក្រោមបញ្ជានៃប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ។

### 2. អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាលមកពីគ្រោះថ្នាក់)៖

ក្រុមហ៊ុន នឹងមិនធ្វើការទូទាត់នូវអត្ថប្រយោជន៍ មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាលមកពីគ្រោះថ្នាក់) ប្រសិនបើ មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ទាំងឡាយណាដែលកើតឡើងដោយផ្ទាល់ ឬប្រយោលពីករណីមិនធានា ត្រង់ចំនុច1 ខាងលើ ឬបណ្តាលមកពីមូលហេតុណាមួយដូចខាងក្រោម៖

ដ. ការស្នើសុំវះកាត់ ដែលសំដៅដល់ការវះកាត់តាមនីតិវិធីក្បួនវេជ្ជសាស្ត្រ រួមទាំងការវះកាត់កែសម្ផស្ស ដោយមិនចាំបាច់ឈរលើមូលដ្ឋានវេជ្ជសាស្ត្រឡើយ ដែលពាក់ព័ន្ធនឹងជីវិតរបស់ ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ដែលស្ថិតក្រោមការការពារនៃផលិតផលនេះ ដែលបានធ្វើឡើងតាមសំណើរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ឬ

ឋ. ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ស្រាបៀរ (ដែលល្មើសនឹងបទប្បញ្ញត្តិច្បាប់ដែលមានចែងក្នុងច្បាប់កម្ពុជាជាធរមាន) ឬ ថ្នាំដែលមិនមានវេជ្ជបញ្ជាត្រឹមត្រូវ ឬ

ឌ. ការប៉ះពាល់ផ្នែករាងកាយ ឬផ្លូវចិត្ត ឬស្ថានភាពចុះខ្សោយ ឬភាពទ្រុឌទ្រោម ដែលត្រូវបានបញ្ជាក់ថាបានកើតឡើងមុនពេលកាលបរិច្ឆេទ មានសុពលភាពនៃបណ្ណសន្យារ៉ាប់រងនេះដោយមិនត្រូវបានប្រកាសឱ្យបានពេញលេញ និងត្រឹមត្រូវ ឬ

ឍ. ចូលរួមក្នុងសកម្មភាពគ្រោះថ្នាក់ រួមទាំងតែមិនកំណត់ចំពោះការជ្រមុជទឹក ការលោតខ្សែយោង ការលោតឆ័ត្រយោង ការឡើងភ្នំ ការប្រណាំងសេះ ឬការប្រណាំងផ្សេងទៀតដែលមានកង់វិលឬ

ណ. អាវុធនុយក្លេអ៊ែរ វិទ្យុសកម្ម ឬវិទ្យុសកម្មពីសារធាតុនុយក្លេអ៊ែរ ឬកាកសំណល់ នុយក្លេអ៊ែរដែលកើតចេញពីការចំហេះនៃសារធាតុនុយក្លេអ៊ែរ និងដំណើរការនៃការបែងចែក ឬការលាយនុយក្លេអ៊ែរដើម្បីទ្រទ្រង់ខ្លួនឯង ឬ

ត. ចូលរួមក្នុងការប្រយុទ្ធ វាយតប់ ឬប្រឆាំងនឹងការចាប់ខ្លួនរបស់មន្ត្រីមានសមត្ថកិច្ច ឬ

ថ. ផលវិបាកពាក់ព័ន្ធផ្សេងទៀត ដោយសារតែការមានផ្ទៃពោះ និងការសម្រាលកូន។

Fortune
LIFE INSURANCE



# ផលិតផល ForLife ចម្រើនទ្រព្យ



**ផលិតផល ForLife ចម្រើនទ្រព្យ៖** គឺជាផលិតផលពិសេសទ្វេដង សម្រាប់លោកអ្នកដែលត្រូវការការការពារ និងការសន្សំក្នុងកញ្ចប់តែមួយ។ ផលិតផល ForLife ចម្រើនទ្រព្យ ផ្តល់ជូនអត្ថប្រយោជន៍ខ្ពស់ ជាមួយបុព្វលាភធានារ៉ាប់រងសមរម្យបំផុត ហើយកាន់តែពិសេសធានាលើអត្ថប្រយោជន៍ដល់កាលកំណត់យ៉ាងជាក់លាក់ ទោះបីមាន ឬមិនមានរឿងអកុសលអ្វីកើតឡើងក៏ដោយ។

## លក្ខខណ្ឌតម្រូវ៖

- អាយុចាប់ផ្តើមធានា៖ **18** ឆ្នាំ ដល់ **65** ឆ្នាំ។
- រយៈពេលនៃបណ្ណសន្យារ៉ាប់រង៖ **5** ឆ្នាំ, **10** ឆ្នាំ និង **15** ឆ្នាំ។
- បុព្វលាភធានារ៉ាប់រងអាចត្រូវបានបង់ជា៖ ប្រចាំឆមាស ឬប្រចាំឆ្នាំ។
- មធ្យោបាយបង់បុព្វលាភ៖ ផ្ទេរតាមធនាគារ បញ្ជាបង់ប្រាក់អចិន្ត្រៃយ៍ សេវាទូទាត់ ឬផ្ទេរប្រាក់មានអាជ្ញាបណ្ណត្រឹមត្រូវ។
- វិសាលភាពនៃការធានា៖ ជាសកលគ្រប់ទីកន្លែង។

## សារៈសំខាន់នៃផលិតផល៖

- ទទួលបានទឹកប្រាក់ត្រលប់តាមកាលកំណត់ **5%** នៃចំនួនទឹកប្រាក់ធានារ៉ាប់រង ប្រសិនបើមិនមាន រឿងអកុសលដែលត្រូវបានធានាអ្វីមួយកើតឡើងរហូតដល់ ចុងឆ្នាំទី3 នៃផលិតផលនេះ។
- ផ្តល់ជូនអត្ថប្រយោជន៍ដល់កាលកំណត់ដែលមានការធានាខ្ពស់ស្មើនឹង **105%** នៃចំនួនទឹកប្រាក់ធានារ៉ាប់រងទោះបីជាអ្នកត្រូវបានធានារ៉ាប់រង ទទួលមរណភាព ឬពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ក៏ដោយ។
- ពុំតម្រូវឱ្យបង់បុព្វលាភធានារ៉ាប់រងបន្តទៀតឡើយក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង ដោយអត្ថប្រយោជន៍ដល់កាលកំណត់នៅតែត្រូវបានផ្តល់ជូនជាធម្មតានៅចុងគ្រានៃផលិតផលនេះ។
- ផ្តល់ជូនការការពារខ្ពស់ទាំងលើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងជាពិសេសរហូតដល់ **300%** នៃចំនួនទឹកប្រាក់ធានារ៉ាប់រងលើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់។

## ករណីខកខាន ឬយឺតយ៉ាវនៃការបង់បុព្វលាភធានារ៉ាប់រង៖

រយៈពេលអនុគ្រោះចំនួន 30 (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដល់កាលកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រង នឹងត្រូវបានផ្តល់ជូនសម្រាប់ការទូទាត់បុព្វលាភធានារ៉ាប់រងដែលមិនទាន់បានបង់ ដែលក្នុងរយៈពេលអនុគ្រោះនេះបណ្ណសន្យារ៉ាប់រងនេះនឹងនៅតែមានសុពលភាពដដែល។

ប្រសិនបើក្រុមហ៊ុននៅតែមិនទទួលបាននូវបុព្វលាភធានារ៉ាប់រង គិតត្រឹមកាលបរិច្ឆេទចុងក្រោយនៃរយៈពេលអនុគ្រោះ នោះបណ្ណសន្យារ៉ាប់រងនឹងអស់សុពលភាព គិតចាប់ពីកាលបរិច្ឆេទដែលត្រូវបង់បុព្វលាភធានារ៉ាប់រងចុងក្រោយ។ ការទទួលខុសត្រូវរបស់ក្រុមហ៊ុននៅក្រោមបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបញ្ចប់ ហើយក្រុមហ៊ុននឹងមិនត្រូវប្រគល់ជូនវិញនូវរាល់បុព្វលាភធានារ៉ាប់រងដែលបានបង់នោះឡើយ។

ម្ចាស់បណ្ណសន្យារ៉ាប់រង អាចដាក់ពាក្យស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញមកក្រុមហ៊ុននៅក្នុងរយៈពេលយ៉ាងយូរបំផុត 2 (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដល់កាលកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រងចុងក្រោយ។



ខិត្តប័ណ្ណនេះផ្តល់នូវព័ត៌មានបឋមអំពីផលិតផលប៉ុណ្ណោះ។ លោកអ្នកត្រូវអានបណ្ណសន្យារ៉ាប់រង នៃផលិតផលនេះ ដើម្បីជ្រាបពីព័ត៌មានលម្អិត ហើយស្វែងរកការប្រឹក្សាយោបល់បុគ្គលិកលក់ផលិតផលធានារ៉ាប់រងរបស់យើងខ្ញុំ មុននឹងសម្រេចចិត្តទិញផលិតផលនេះ។


Fortune Life Insurance PLC | fortunelifecambodia
www.fortunelife.com.kh | +855 23 931 999 | 1800-202 202 ឥតគិតថ្លៃ
អគារ The Gateway ជាន់ទី26 មហាវិថីសហព័ន្ធរុស្សី (ផ្លូវ110) សង្កាត់ផ្សារដេប៉ូទី3 ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា